ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# គោលនយោបាយស្តីពីគ្រូបង្រៀន

## ផែនការសកម្មភាព

នាយកដ្ឋានបណ្តុះបណ្តាល និងវគ្រូកការ

ខែមករា ឆ្នាំ២០១៥

# មាតិកា


អារម្ភកថា....3

ពាក្យកាត់និងអក្សរសម្គាល់ ....4

សង្ខេបសកម្មភាពសំខាន់ៗ ....5

១.សារបាន ....6

១.១គោលនយោបាយស្តីពីគ្រូបង្រៀន(ឆ្នាំ២០១៣)....6

១.២ស្ថានភាពនិងបញ្ហាអាទិភាព ....6

២.យុទ្ធសាស្ត្រ....8

៣.ផែនការសកម្មភាព....8

៤.កាលវិភាគរៀបចំសេចក្តីព្រាងច្បាប់.លិខិតបទដ្ឋានគតិយុត្ត ....24

៥.គម្រោងចំណាយ ....24

៦.ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ....25

៧.សេចក្តីសន្និដ្ឋាន ....26

ឧបសម្ព័ន្ធ....27

តារាងគណនាតម្លៃ ....27

# អារម្ភកថា

ដើម្បីរួមចំណែកអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា បានកសាងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨ ក្នុងគោលបំណងអភិវឌ្ឍមូលធនមនុស្សសម្រាប់ប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០និងប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០។ ដើម្បីឆ្លើយតបនឹងចក្ខុវិស័យខាងលើ គ្រូបង្រៀនដែលមានសមត្ថភាពខ្ពស់គឺជាកត្តាគន្លឹះក្នុងការជួយសិស្សឱ្យសម្រេចបានលទ្ធផលល្អប្រសើរក្នុងការសិក្សា។ វិធានការអាទិភាពមួយចំនួននឹងត្រូវអនុវត្តដើម្បីសម្រេចជោគជ័យក្នុងកំណែទម្រង់គ្រូបង្រៀន ដូចជាការត្រៀមរៀបចំឯកសារក្របខណ្ឌគតិយុត្ត ការជ្រើសរើស ការបណ្តុះបណ្តាល ការបែងចែក ការគាំទ្រគ្រប់ផ្នែក និងការវាយតម្លៃ។ បច្ចុប្បន្ន ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូពាក់ព័ន្ធកំពុងយកចិត្តទុកដាក់ក្នុងការបង្កើតយន្តការទាក់ទាញអ្នកដែលមានសមត្ថភាពនិងមានចំណូលចិត្តឱ្យចូលធ្វើការក្នុងវិជ្ជាជីវៈគ្រូបង្រៀន។ ការជ្រើសរើសនិងការបណ្តុះបណ្តាលគ្រូបង្រៀនដ៏មានប្រសិទ្ធភាពគឺជាគន្លឹះនៃកំណែទម្រង់ប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន និងជាយន្តការធានាថា ឋានៈនិងតួនាទីរបស់គ្រូបង្រៀនក្នុងសង្គមត្រូវបានឱ្យតម្លៃនិងលើកកម្ពស់។

ការអនុម័តគោលនយោបាយស្តីពីគ្រូបង្រៀននៅឆ្នាំ២០១៣ គឺជាការចាប់ផ្តើមនៃការធ្វើកំណែទម្រង់ប្រព័ន្ធបណ្តុះបណ្តាលនិងការជ្រើសរើសគ្រូបង្រៀន។ គោលនយោបាយស្តីពីគ្រូបង្រៀនបានដាក់ចេញនូវគោលបំណង គោលដៅ និងយុទ្ធសាស្ត្រមួយចំនួនសម្រាប់អនុវត្ត។ ការកសាងផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយគ្រូបង្រៀនជាជំហានបន្ទាប់ដែលមានគោលបំណងផ្តល់ការចង្អុលទិសមួយច្បាស់លាស់ដល់អ្នកពាក់ព័ន្ធសម្រាប់ការធ្វើកំណែទម្រង់ជាប្រព័ន្ធក៏ដូចជាសម្រាប់ការអនុវត្ត។ ផែនការសកម្មភាពនេះមានបញ្ចូលកម្មវិធី សកម្មភាព កាលបរិច្ឆេទលទ្ធផលរំពឹងទុក និងការធ្វើចំណោលថវិកាសម្រាប់អនុវត្តពីឆ្នាំ២០១៥ ដល់ឆ្នាំ២០២០។ ផែនការសកម្មភាពនេះមានគោលបំណង៖

- រៀបចំចក្ខុវិស័យថ្មីមួយសម្រាប់វិជ្ជាជីវៈគ្រូបង្រៀននៅកម្ពុជា
- ពង្រឹងគុណភាពអប់រំនៅគ្រប់ភូមិសិក្សា
- ធ្វើកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនទាំងអស់ (សាលាគរុកោសល្យ គ្រឹះស្ថានឧត្តមសិក្សា ។ល។)
- ផ្តល់ការលើកទឹកចិត្តទាំងផ្នែកសម្ភារៈនិងមិនមែនសម្ភារៈ ជាពិសេសឋានៈវិជ្ជាជីវៈគ្រូបង្រៀន
- ធ្វើការផ្លាស់ប្តូរគោលការណ៍សំខាន់ៗនៃរបៀបបង្រៀននិងរៀនដែលកំពុងអនុវត្តបច្ចុប្បន្ន សំដៅឈានទៅសម្រេចបានលទ្ធផលសិក្សារបស់សិស្សខ្ពស់
- ធានាការចូលរួម ការប្តេជ្ញាចិត្ត និងការមានចក្ខុវិស័យរួមពីគ្រប់អ្នកពាក់ព័ន្ធនិងដៃគូអភិវឌ្ឍទាំងអស់
- រៀបចំមូលដ្ឋានគ្រឹះសម្រាប់ធ្វើកំណែទម្រង់ស៊ីជម្រៅក្នុងការបណ្តុះបណ្តាលគ្រូបង្រៀននៅក្រោយឆ្នាំ២០២០។

ក្រសួងអប់រំ យុវជន និងកីឡាសូមថ្លែងអំណរគុណដល់កិច្ចសហការដ៏ល្អរវាងនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ក្រុមប្រឹក្សាស្រាវជ្រាវអប់រំ ក្រុមការងារវិស័យអប់រំ ពិសេសអង្គការថៃការ យូណេស្កូ យូនីសេហ្វ ភាពជាដៃគូអប់រំនៃអង្គការមិនមែនរដ្ឋាភិបាល ធនាគារពិភពលោក សហគមន៍អឺរ៉ុប និងភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត។ ក្រសួង សង្ឃឹមថាផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀននេះនឹងជាប្រទីបបង្ហាញផ្លូវមួយសម្រាប់ការធ្វើកំណែទម្រង់ប្រព័ន្ធបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀនឲ្យបានស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ។ ផែនការនេះជាត្រីវិស័យសម្រាប់អាជ្ញាធរអប់រំ អង្គភាពជំនាញ និងដៃគូពាក់ព័ន្ធគ្រប់កម្រិតថ្នាក់យកទៅអនុវត្តសំដៅលើកកម្ពស់ប្រសិទ្ធភាពនិងគុណភាពអប់រំ។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែ មករា ឆ្នាំ២០១៤

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

បណ្ឌិត ហង់ ជួន ណារ៉ុន

# ពាក្យកាត់និងអក្សរសម្គាល់

| | |
|---|---|
| ការិ.អយក | ការិយាល័យអប់រំយុវជននិងកីឡាក្រុង/ស្រុក/ ខណ្ឌ |
| គ្រឹ. | គ្រឹះស្ថាន |
| នា.តទវ | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ |
| នា.ធគអ | នាយកដ្ឋានធានាគុណភាពអប់រំ |
| នា.នីតិ | នាយកដ្ឋាននីតិកម្ម |
| នា.បល | នាយកដ្ឋានបុគ្គលិក |
| នា.បវ | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ |
| នា.បស | នាយកដ្ឋានបឋមសិក្សា |
| នា.ផក | នាយកដ្ឋានផែនការ |
| នា.ពអស៊ | នាយកដ្ឋានព័ត៌មាននិងកិច្ចការអាស៊ាន |
| នា.មចទ | នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ |
| នា.សវ | នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ |
| នា.សំណង់ | នាយកដ្ឋានសំណង់ |
| នា.សទរ | នាយកដ្ឋានសម្ភារៈនិងទ្រព្យសម្បត្តិរដ្ឋ |
| នា.សស | នាយកដ្ឋានសុខភាពសិក្សា |
| នា.ហវ | នាយកដ្ឋានហិរញ្ញវត្ថុ |
| នា.ទវអ | នាយកដ្ឋានទំនាក់ទំនងវប្បធម៌និងអាហារូបករណ៍ |
| នា.អកត | នាយកដ្ឋានអប់រំកុមារតូច |
| នា.អកប | នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| នា.អកស | នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| នា.ឧស | នាយកដ្ឋានឧត្តមសិក្សា |
| ប.ប | បណ្តុះបណ្តាល |
| មន្ទីរអយក | មន្ទីរអយករាជធានី-ខេត្ត |
| វជអ | វិទ្យាស្ថានជាតិអប់រំ |
| វអក | វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា |
| ស.ប | សញ្ញាបត្រ |
| សភភព | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| អយក | អប់រំយុវជននិងកីឡា |
| ឧ. | ឧទាហរណ៍ |
| CDPF | មូលនិធិដៃគូសម្រាប់ការកសាងសមត្ថភាព |
| EMIS | ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ |
| FMIS | ប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ |
| HEMIS | ប្រព័ន្ធព័ត៌មានគ្រប់គ្រងឧត្តមសិក្សា |
| HRMIS | ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស |
| ICT | បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ |
| IT | បច្ចេកវិទ្យានិងព័ត៌មាន |
| NEFAC | គណៈកម្មការជាតិអប់រំសម្រាប់ទាំងអស់គ្នា |
| NFMIS | ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ |
| NGO | អង្គការក្រៅរដ្ឋាភិបាល |
| PB | ថវិកាកម្មវិធី |
| Q1,Q2 .... | ត្រីមាសទី១ត្រីមាសទី២... |
| SIG | ថវិកាជំនួយដើម្បីកែលម្អសាលារៀន |
| SOB | ថវិកាដំណើរការសាលារៀន |
| USD | ជាដុល្លារអាមេរិក |

# សង្ខេបសកម្មភាពសំខាន់ៗ

ជោគជ័យនៃការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀនអាស្រ័យលើភាពជោគជ័យនៃការអនុវត្តសកម្មភាពនីមួយៗ។ផែនការលម្អិតសម្រាប់អនុវត្តសកម្មភាពនីមួយៗត្រូវបានលើកឡើងនៅក្នុងតារាងម៉ាទ្រិចនៃផែនការសកម្មភាពពីទំព័រទី៨ដល់ទី២៣។រាល់សកម្មភាពទាំងអស់ត្រូវបានរៀបចំឡើងដោយផ្អែកលើការពិគ្រោះឯកសារការសិក្សាស្ថានភាពជាក់ស្តែងមេរៀនពិសោធន៍ល្អៗក្នុងតំបន់និងការងារជាអាទិភាពសំខាន់ៗរបស់ក្រសួងអប់រំ យុវជន និងកីឡាដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤- ២០១៨។

| ផ្នែកសំខាន់ៗ | សកម្មភាពសម្រាប់រយៈពេលខ្លី(២០១៥-២០១៧) | សកម្មភាពសម្រាប់រយៈពេលមធ្យម(២០១៨-២០២០) |
|---|---|---|
| **១.ការជ្រើសរើសនិងការបណ្តុះបណ្តាលគ្រូបង្រៀន** | • ទទួលយកបេក្ខជនដែលបាននិទ្ទេសA, BនិងCពីការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឱ្យចូលសិក្សាក្នុងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនជាស្វ័យប្រវត្តិ<br>• បង្កើតច្រកចូលច្រើនដើម្បីធ្វើជាគ្រូបង្រៀនដោយបើកទូលាយការបណ្តុះបណ្តាលបេក្ខជនបរិញ្ញាបត្រនៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈនិងគ្រឹះស្ថានឧត្តមសិក្សាឯកជនឱ្យទទួលបានអាជ្ញាបណ្ណគ្រូបង្រៀន<br>• រៀបចំវគ្គបណ្តុះបណ្តាលគរុកោសល្យរយៈពេលខ្លីសម្រាប់អ្នកមានសញ្ញាបត្រឱ្យក្លាយជាគ្រូបង្រៀនកម្រិតមូលដ្ឋានដោយសហការជាមួយគ្រឹះស្ថានឧត្តមសិក្សា<br>• ដំឡើងប្រាក់ខែ និងបន្ថែមផលប្រយោជន៍ផ្សេងៗឱ្យគ្រូបង្រៀនរហូតដល់កម្រិតខ្ពស់ជាងមុខតំណែងនៃវិជ្ជាជីវៈផ្សេងៗដែលមានគុណវុឌ្ឍិប្រហាក់ប្រហែលគ្នា<br>• អនុវត្តស្តង់ដារគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន<br>• ពង្រឹងនិងពង្រីកគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងស្តង់ដារគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនដើម្បីលើកកម្ពស់គុណភាពបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀន | • អនុវត្តសាកល្បងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនតាមរូបមន្ត12+4នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគភ្នំពេញនិងបាត់ដំបង<br>• អនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនតាមរូបមន្តបរិញ្ញាបត្របូក១នៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន<br>• ប្រែក្លាយគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនឱ្យទៅជាវិទ្យាស្ថានបណ្តុះបណ្តាលគ្រូបង្រៀន |
| **២.ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន** | • បង្កើនគុណវុឌ្ឍិគ្រូឧទ្ទេសនៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនឱ្យមានកម្រិតយ៉ាងទាបបរិញ្ញាបត្រជាន់ខ្ពស់<br>• បង្កើនគុណវុឌ្ឍិគ្រូបង្រៀនឱ្យទទួលបានសញ្ញាបត្របរិញ្ញាបត្រតាមរយៈកម្មវិធីបណ្តុះបណ្តាលពន្លឿន<br>• រៀបចំប្រព័ន្ធវិក្រឹតការគ្រូបង្រៀននៅនឹងកន្លែង<br>• បង្កើតការប្រឡងប្រណាំងពានរង្វាន់គ្រូបង្រៀនទូទាំងប្រទេសដើម្បីផ្តល់រង្វាន់ដល់គ្រូបង្រៀនឆ្នើម | • ប្រើប្រាស់ការធ្វើវិក្រឹតការបែបប្រព័ន្ធក្រេឌីតសម្រាប់លើកទឹកចិត្តគ្រូបង្រៀនតាមគន្លងអាជីពគ្រូបង្រៀន<br>• បង្កើតការប្រឡងប្រណាំងគ្រូបង្រៀនថ្នាក់ជាតិដើម្បីផ្តល់ពានរង្វាន់ដល់គ្រូបង្រៀនឆ្នើមនិងដើម្បីចែករំលែកបទពិសោធន៍ល្អៗ |
| **៣.ការគ្រប់គ្រងនិងការបង្កើតគន្លងអាជីពគ្រូបង្រៀន** | • ពង្រឹងការគ្រប់គ្រងគ្រូបង្រៀនការពង្រាយគ្រូបង្រៀននិងការផ្ទេរគ្រូបង្រៀនពីតំបន់មួយទៅតំបន់មួយ<br>• បង្កើតគន្លងអាជីពគ្រូបង្រៀនដើម្បីការអភិវឌ្ឍនិងវឌ្ឍនភាពវិជ្ជាជីវៈគ្រូបង្រៀន | • បង្កើតកញ្ចប់ឯកសារជំនួយសម្រាប់គ្រូបង្រៀនថ្មីដែលធ្វើកម្មសិក្សាទាំងអស់ (ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនឯកសារណែនាំស្តីពីស្វ័យភាពគ្រូបង្រៀនគន្លងអាជីពគ្រូបង្រៀននិងលិខិតបទដ្ឋានគតិយុត្តទាក់ទងផ្សេងទៀត) |
| **៤.បរិស្ថានសាលារៀន** | • បំពាក់ហេដ្ឋារចនាសម្ព័ន្ធគ្រឹះស្ថានសិក្សាៈបន្ទប់រៀនបង្គន់អនាម័យផ្ទះគ្រូបង្រៀនសាលសាស្ត្រាចារ្យបណ្ណាល័យ ។ល។ | • សង់និងពង្រីកហេដ្ឋារចនាសម្ព័ន្ធសាលារៀននៅតំបន់ដាច់ស្រយាលនិងជនបទដើម្បីលើកកម្ពស់លក្ខខណ្ឌបំពេញការងាររបស់គ្រូបង្រៀន |
| សៀវភៅសិក្សា | • ផ្តល់សៀវភៅសិក្សានិងផលិតសៀវភៅគ្រូលើមុខវិជ្ជាដែលត្រូវបំប៉នបន្ថែម(ភាសាខ្មែរ ប្រវត្តិវិទ្យា គណិតវិទ្យា វិទ្យាសាស្ត្រ) | • ផ្តល់ឯកសារបង្រៀននិងរៀនបន្ថែមសម្រាប់ជួយគាំទ្រគ្រូបង្រៀន |
| កម្មវិធីសិក្សា | • ធ្វើបច្ចុប្បន្នភាពនិងទំនើបកម្មនៃកម្មវិធីសិក្សាសម្រាប់បណ្តុះបណ្តាលគ្រូបង្រៀនគ្រប់កម្រិត | • បង្កើនគុណភាពការបណ្តុះបណ្តាលគ្រូបង្រៀនស្របតាមស្តង់ដារប្រទេសអាស៊ានដែលខ្ពស់ជាងគេ |
| អធិការកិច្ច | • អនុវត្តឱ្យមានប្រសិទ្ធភាពនូវស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀននិងបង្កើតស្តង់ដារនាយកសាលា<br>• រៀបចំសៀវភៅណែនាំការគ្រប់គ្រងសាលារៀនដើម្បីពង្រឹងប្រសិទ្ធភាពនៃការដឹកនាំនិងគ្រប់គ្រងសាលារៀន<br>• ពង្រឹងការអនុវត្តតួនាទីនិងភារកិច្ចរបស់នាយកសាលាគ្រូបង្រៀននិងគ្រូឧទ្ទេសឱ្យបំពេញភារកិច្ចដោយការទទួលខុសត្រូវ<br>• ធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងនិងសិទ្ធិធ្វើសេចក្តីសម្រេចសំខាន់ៗទៅថ្នាក់គ្រឹះស្ថានសិក្សាតាមគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការរបស់ក្រសួងអប់រំ យុវជន និងកីឡា | • ធ្វើពិពិធកម្មរាល់ធាតុចូលទាំងអស់រួមទាំងការជំរុញការប្រើប្រាស់មតិត្រឡប់របស់សហគមន៍អំពីគ្រូបង្រៀននិងគ្រឹះស្ថានសិក្សា<br>• បង្កើនប្រសិទ្ធភាពការអនុវត្តយន្តការតាមដាននិងទំនុកបម្រុងគ្រូបង្រៀននៅនឹងកន្លែងដោយគណៈគ្រប់គ្រងសាលារៀន |

# ១.សារផ្ទាន

## *១.១គោលនយោបាយស្តីពីគ្រូបង្រៀន(ឆ្នាំ២០១៣)*

គោលនយោបាយស្តីពីគ្រូបង្រៀនបានដាក់ចេញនូវចក្ខុវិស័យគោលបំណងនិងគោលដៅសំខាន់ៗដូចខាងក្រោម៖

- **ចក្ខុវិស័យ**៖កសាងគ្រូបង្រៀនឱ្យមានចំណេះដឹងជំនាញសីលធម៌និងមានសមត្ថភាពអនុវត្តវិជ្ជាជីវៈដោយមានការទទួលស្គាល់ពីសង្គម។
- **គោលបំណង**៖អភិវឌ្ឍគ្រូបង្រៀនឱ្យមានគុណភាពសមត្ថភាព ស្មារតីទទួលខុសត្រូវស្របតាមក្រមសីលធម៌វិជ្ជាជីវៈនិងផ្តល់លក្ខខណ្ឌចាំបាច់ក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងភាពសក្តិសិទ្ធិ។
- **គោលដៅ**៖

១.ទាក់ទាញនិងលើកទឹកចិត្តអ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន។

២.ធានាការបណ្តុះបណ្តាលមុនពេលបម្រើការងារជាគ្រូបង្រៀន។

៣.ធានាការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារជាប់ជាប្រចាំ។

៤.ធានាលក្ខខណ្ឌចាំបាច់ចំពោះគ្រូបង្រៀនក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងភាពសក្តិសិទ្ធិ។

## *១.២ ស្ថានភាពនិងបញ្ហាអាទិភាព*

ក្នុងឆ្នាំសិក្សា២០១៣-១៤ក្រសួងអប់រំ យុវជន និងកីឡាមានបុគ្គលិកបង្រៀនសរុបស្មើនឹង៨៣%ធៀបនឹងបុគ្គលិកទាំងអស់។បច្ចុប្បន្នក្នុងចំណោមបុគ្គលិកបង្រៀនសរុប៨៨.៨១៨នាក់គ្រូបង្រៀននៅសាលាបឋមសិក្សាមាន៥២%នៅមធ្យមសិក្សាបឋមភូមិមាន៣១%នៅមធ្យមសិក្សាទុតិយភូមិមាន១២% និងនៅមត្តេយ្យសិក្សាមាន៥%។បញ្ហាដែលគួរយកចិត្តទុកដាក់ក្នុងការផ្គត់ផ្គង់គ្រូបង្រៀនគឺលំហូរចេញពីក្របខ័ណ្ឌគ្រូបង្រៀនដែលមាន២.០១៧នាក់នៅឆ្នាំ២០១២និង២.១៣៧នាក់នៅឆ្នាំ២០១៣។ចំនួននេះមានទំហំធំបើធៀបនឹងចំនួនក្របខ័ណ្ឌថ្មីដែលក្រសួងអប់រំ យុវជន និងកីឡាត្រូវបណ្តុះបណ្តាលរៀងរាល់ឆ្នាំចំនួនប្រមាណ៥.០០០នាក់។នៅកម្រិតមធ្យមសិក្សាទុតិយភូមិអត្រាវិចវិលរបស់គ្រូបង្រៀននៅតែបន្តកើនឡើងដែលបង្កបញ្ហាដល់ការផ្គត់ផ្គង់គ្រូបង្រៀននិងធ្វើឱ្យប៉ះពាល់ដល់គុណភាពសិក្សារបស់សិស្ស។ការប្រើប្រាស់គ្រូបង្រៀនដែលរួមបញ្ចូលទាំងការពង្រាយនិងផលធៀបគ្រូ-សិស្សមិនទាន់បានអនុវត្តឱ្យបានត្រឹមត្រូវតាមគោលការណ៍នៅឡើយទេ។

កន្លងមកដោយសារកត្តាប្រវត្តិសាស្រ្ត ភូមិសាស្រ្ត និងសង្គម-សេដ្ឋកិច្ច ក្រសួងអប់រំ យុវជន និងកីឡាបានប្រើរូបមន្តច្រើនសម្រាប់បណ្តុះបណ្តាលគ្រូបង្រៀន។ចាប់ពីដើមទសវត្សរ៍ឆ្នាំ១៩៨០ រយៈពេលនៃការបណ្តុះបណ្តាលដែលផ្តល់ដោយក្រសួងគឺមានការកើនឡើង ចាប់ពី៤ខែ៧ខែ ឈានទៅប្រើប្រាស់រូបមន្ត៣+១, ៨+១, ៥+៣, ៧+១, ៨+១, ៧+៣, ១០+៣, ១០+៤, ១១+១, ១២+១, ១២+២ រហូតដល់បរិញ្ញាបត្របូក១។ មកដល់ពេលនេះ ការបណ្តុះបណ្តាលគ្រូបង្រៀនតាមរូបមន្តទាបៗ (ទាបជាងបរិញ្ញាបត្របូក១) មានចំនួន១១១ជំនាន់

និងបានបណ្តុះបណ្តាលគ្រូបង្រៀនប្រមាណ១០២.០០០នាក់[1]។ នៅឆ្នាំ ២០២០ ក្រសួងអប់រំ យុវជន និងកីឡាមានបំណងឱ្យគ្រូបង្រៀនកម្រិតមូលដ្ឋានទទួលបានស្តង់ដារគុណវុឌ្ឍិបរិញ្ញាបត្របូក១ឬ 12+4 និងគ្រូបង្រៀនកម្រិតឧត្តមទទួលបានគុណវុឌ្ឍិបរិញ្ញាបត្រជាន់ខ្ពស់បូក១។ បច្ចុប្បន្នគ្រូបង្រៀនដែលមានគុណវុឌ្ឍិទាបជាងសញ្ញាបត្របរិញ្ញាបត្រមានចំនួនជាង ៧៥.០០០នាក់ (EMIS, ២០១៣) ហើយអត្រាអ្នកដែលមានសញ្ញាបត្របរិញ្ញាបត្រមានការកើនឡើងប្រមាណ២%ក្នុងមួយឆ្នាំ។តួលេខនេះបង្ហាញថា បើសិនជាគ្មានគោលនយោបាយ និងអន្តរាគមន៍បន្ថែមទេ នៅឆ្នាំ២០២០ អ្នកដែលមានសញ្ញាបត្របរិញ្ញាបត្រនឹងមានត្រឹមតែ២៨%ប៉ុណ្ណោះ។ ដូច្នេះ កិច្ចការដែលត្រូវធ្វើជាបន្ទាន់សម្រាប់ការបណ្តុះបណ្តាលនិងវិក្រឹតការគឺត្រូវធានាថាគ្រូបង្រៀនមានឱកាសអភិវឌ្ឍវិជ្ជាជីវៈដើម្បីទទួលបានគុណវុឌ្ឍិកម្រិតបរិញ្ញាបត្រ។

ការលំបាកក្នុងការទាក់ទាញបេក្ខជនរៀនពូកែឱ្យមកចូលធ្វើគ្រូបង្រៀនគឺមកពីស្ថានភាពសង្គមរបស់គ្រូបង្រៀននៅមានកម្រិតទាបនៅឡើយ។ បច្ចុប្បន្ន គ្រូបង្រៀនទទួលបៀវត្សស្មើនឹង ៦០% នៃបៀវត្សរបស់អ្នកមានវិជ្ជាជីវៈផ្សេងទៀតក្នុងវិស័យឯកជនដែលមានគុណវុឌ្ឍិនិងបំណិនប្រហាក់ប្រហែលគ្នា។គ្រូបង្រៀនជាច្រើនបានបង្ខំចិត្តប្រកបមុខរបរទីពីរដែលបានទទួលកម្រៃតិចតួចបន្ថែមសម្រាប់ទ្រទ្រង់ជីវភាពរស់នៅ។ទង្វើនេះបានធ្វើឱ្យសហគមន៍ជុំវិញពួកគាត់ឱ្យតម្លៃទាបដល់វិជ្ជាជីវៈនិងឋានៈគ្រូបង្រៀននៅក្នុងសង្គម។អាស្រ័យហេតុនេះ ទើបកន្លងមកមានគរុសិស្ស/គរុនិស្សិតជាង៨០%ដែលប្រឡងចូលគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនមាននិទ្ទេស(សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ)ត្រឹមតែDឬEប៉ុណ្ណោះ។វិជ្ជាជីវៈគ្រូបង្រៀនពុំត្រូវបានសិស្សពូកែឱ្យតម្លៃថាជាវិជ្ជាជីវៈសំខាន់និងជាជម្រើសអាជីពដែលគួរឱ្យពេញចិត្តរបស់ពួកគាត់ទេ។ដូច្នេះអាទិភាពបន្ទាន់សម្រាប់រយៈពេលខ្លីនិងមធ្យមគឺត្រូវបង្កើនការទាក់ទាញបេក្ខជនដែលពូកែឱ្យចូលក្នុងវិជ្ជាជីវៈគ្រូបង្រៀននិងផ្តល់ការបណ្តុះបណ្តាលដែលមានរយៈពេលខ្លីចំពោះបេក្ខជនដែលមានគុណវុឌ្ឍិខ្ពស់ព្រមទាំងការបង្កើតច្រកចូលច្រើនសម្រាប់ចូលធ្វើជាគ្រូបង្រៀនដែលអនុញ្ញាតឱ្យនិស្សិតដែលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យឆាប់បានទៅជួយបង្រៀនសិស្សក្នុងថ្នាក់។

នៅពេលចូលក្នុងវិជ្ជាជីវៈគ្រូបង្រៀនគ្រូបង្រៀនភាគច្រើនពុំមានឱកាសក្នុងការបន្តការអភិវឌ្ឍវិជ្ជាជីវៈទេ។កន្លងមកក្រសួងអប់រំ យុវជន និងកីឡានិងដៃគូអភិវឌ្ឍបានធ្វើវិក្រឹតការនៅនឹងកន្លែងនិងវិក្រឹតការមិនរៀបរយរយៈពេលខ្លីប៉ុន្តែប្រសិទ្ធភាពនៅមានកម្រិតទាប។ វិក្រឹតការរៀបរយរយៈពេលវែងដែលមានប្រព័ន្ធនិងកម្មវិធីច្បាស់លាស់ពុំត្រូវបានអនុវត្តនោះទេ។ក្នុងសន្និបាតអប់រំថ្មីៗនេះមានអង្គភាពជិត៥០ដែលធ្វើសកម្មភាពពាក់ព័ន្ធនឹងសេវាកម្មវិក្រឹតការគ្រូបង្រៀនតែសកម្មភាពទាំងនោះបំពេញតម្រូវការគ្រូបង្រៀនបានមួយភាគតូចប៉ុណ្ណោះដោយសារតែកង្វះកម្មវិធីវិក្រឹតការឬចក្ខុវិស័យរួមនិងការអនុវត្តការពិនិត្យតាមដានពុំច្បាស់លាស់។ជាមួយគ្នានេះគ្រូបង្រៀនដែលបានចូលរួមក្នុងវគ្គវិក្រឹតការទទួលបានការលើកទឹកចិត្តតិចតួចដោយសារតែការអភិវឌ្ឍវិជ្ជាជីវៈពុំមានភ្ជាប់ទៅនឹងការដំឡើងឋានៈឬវឌ្ឍនភាពអាជីពសម្រាប់រយៈពេលវែង។ការរៀបចំប្រព័ន្ធវិក្រឹតការដើម្បីធ្វើសមមូលភាពភ្ជាប់នឹងការលើកទឹកចិត្តជាក់លាក់ដូចជាការផ្តល់ក្រេឌីតការដំឡើងឋានៈការបង្កើនបៀវត្សការបង្កើនគុណវុឌ្ឍិ។ល។ពិសេសការភ្ជាប់ទៅនឹងគន្លងអាជីពគ្រូបង្រៀនមានសារៈសំខាន់ណាស់។

បើសិនជាមិនអាចទាក់ទាញអ្នកដែលរៀនពូកែមិនបានបណ្តុះបណ្តាលគ្រូបង្រៀនឱ្យទទួលបានកម្រិតគុណវុឌ្ឍិយ៉ាងទាបកម្រិតបរិញ្ញាបត្រនិងមិនបានផ្តល់ឱកាសដល់គ្រូបង្រៀនសម្រាប់អភិវឌ្ឍវិជ្ជាជីវៈនោះគឺប្រាកដណាស់ថាគ្រូបង្រៀននៅតែមានគុណភាពទាបនិងឋានៈគ្រូបង្រៀនក៏នឹងមិនត្រូវបានលើកតម្កើងដែរ។កង្វះគ្រូពូកែជាដើមហេតុនៃលទ្ធផលសិក្សាខ្សោយរបស់សិស្សដែលឆ្លុះបញ្ចាំងតាមរយៈលទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំសិក្សា២០១៣-២០១៤ ដែលបង្ហាញពីការយល់ដឹងទាបរបស់សិស្សលើមុខវិជ្ជាមួយចំនួន (ឧ.គណិតវិទ្យា) និងមានគម្លាតស្តង់ដារធំដែលបង្ហាញពីរបាយពិន្ទុរបស់សិស្សក្នុងចំណោមក្រុមមុខវិជ្ជា។ទោះបីជាមានកត្តាច្រើនទៀតដែលត្រូវយកចិត្តទុកដាក់ដូចជាកម្មវិធីសិក្សាសៀវភៅសិក្សាសម្ភារៈបរិក្ខារសិក្សានិងបរិស្ថានសាលារៀនក៏ដោយក៏គ្រូបង្រៀននៅតែជាកត្តាមួយដ៏សំខាន់ក្នុងប្រព័ន្ធអប់រំដែលរួមចំណែកដល់លទ្ធផលនេះ។

---

[1] ចំនួននេះមិនបានបញ្ចូលទិន្នន័យតាមឆ្នាំសិក្សាមួយចំនួន។ប្រភពនា.បវ (២០១៤)

សរុបមកស្ថានភាពបច្ចុប្បន្នបានបង្ហាញថាក្រសួងអប់រំ យុវជន និងកីឡាត្រូវរៀបចំវិធានការកែលម្អប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀនជាបន្ទាន់ពិសេសសម្រាប់រយៈពេលខ្លី។ដូច្នេះផែនការសកម្មភាពនេះត្រូវបានអភិវឌ្ឍឡើងចំពេលវេលានិងមានសារៈសំខាន់ណាស់ព្រោះផែនការនេះបានដាក់ចេញនូវសកម្មភាពច្បាស់លាស់អំពីរបៀបធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀននិងបានបើកច្រកថ្មីៗជាច្រើនសម្រាប់អ្នកមានសមត្ថភាពឱ្យចូលធ្វើការក្នុងវិជ្ជាជីវៈគ្រូបង្រៀនសំដៅឆ្លើយតបនឹងតម្រូវការអភិវឌ្ឍធនធានមនុស្សនៅមូលដ្ឋានជាពិសេសនៅសាលារៀនជំនាន់ថ្មី។

## ២.យុទ្ធសាស្ត្រ

ដើម្បីសម្រេចគោលដៅទាំងបួននៃគោលនយោបាយស្តីពីគ្រូបង្រៀនក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញយុទ្ធសាស្ត្រសំខាន់ៗចំនួន៩និងយុទ្ធសាស្ត្ររងចំនួន៣៤ (សូមមើលផ្នែកទី៣ផែនការសកម្មភាព)។កម្មវិធីនិងសកម្មភាពទាំងអស់ក្នុងផែនការសកម្មភាពនេះត្រូវបានកសាងឡើងស្របតាមយុទ្ធសាស្ត្រនិងយុទ្ធសាស្ត្ររងទាំងនេះ។

យុទ្ធសាស្ត្រទី១.កសាងលិខិតបទដ្ឋានគតិយុត្តនិងយន្តការ
យុទ្ធសាស្ត្រទី២.ទាក់ទាញអ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈគ្រូបង្រៀន
យុទ្ធសាស្ត្រទី៣.កំណត់ស្តង់ដារប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន
យុទ្ធសាស្ត្រទី៤.អភិវឌ្ឍគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន
យុទ្ធសាស្ត្រទី៥.ធ្វើសនិទានកម្មគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់គ្រឹះស្ថានសិក្សា
យុទ្ធសាស្ត្រទី៦.អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារ
យុទ្ធសាស្ត្រទី៧.លើកទឹកចិត្តនិងរក្សាទុកគ្រូបង្រៀន
យុទ្ធសាស្ត្រទី៨.ពង្រឹងប្រសិទ្ធភាពជាអ្នកដឹកនាំសាលារៀន
យុទ្ធសាស្ត្រទី៩.ពង្រឹងប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃគ្រូបង្រៀន

## ៣.ផែនការសកម្មភាព

| កម្មវិធី/សកម្មភាពគោល | កិច្ចការ/សកម្មភាព | សូចនាករ | ពេលបញ្ចប់សកម្មភាព | អង្គភាពទទួលខុសត្រូវ | ថវិកា(USD) |
|---|---|---|---|---|---|
| **យុទ្ធសាស្ត្រទី១. កសាងលិខិតបទដ្ឋានគតិយុត្តនិងយន្តការ** | | | | | |
| យុទ្ធសាស្ត្ររងទី១.១ពិនិត្យឡើងវិញកែលម្អនិងកសាងលិខិតបទដ្ឋានគតិយុត្ត | | | | | |
| | មាននៅតាមសកម្មភាពនៃយុទ្ធសាស្ត្រទី២-ទី៩ | ដូចក្នុងសកម្មភាពត្រូវគ្នាក្នុងយុទ្ធសាស្ត្រទី២-៩ | ដូចក្នុងសកម្មភាពត្រូវគ្នាក្នុងយុទ្ធសាស្ត្រទី២-៩ | នា.នីតិ និងនាយកដ្ឋានពាក់ព័ន្ធ (អនុក្រឹត៨៤) | $0 |
| យុទ្ធសាស្ត្ររងទី១.២កសាងយន្តការចាំបាច់សម្រាប់ផ្សព្វផ្សាយអនុវត្តគាំទ្រពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តគោលនយោបាយ | | | | | |
| | មាននៅតាមសកម្មភាពនៃយុទ្ធសាស្ត្រទី២-ទី៩ | ដូចក្នុងសកម្មភាពត្រូវគ្នាក្នុងយុទ្ធសាស្ត្រទី២-៩ | ដូចក្នុងសកម្មភាពត្រូវគ្នាក្នុងយុទ្ធសាស្ត្រទី២-៩ | នា.នីតិ និងនាយកដ្ឋានពាក់ព័ន្ធ (អនុក្រឹត៨៤ | $0 |

| កម្មវិធី/សកម្មភាពគោល | | កិច្ចការ/សកម្មភាព | | សូចនាករ | ពេលបញ្ចប់សកម្មភាព | អង្គភាពទទួលខុសត្រូវ | ថវិកា(USD) |
|---|---|---|---|---|---|---|---|
| **យុទ្ធសាស្ត្ររងទី១.៣កសាងផែនការសកម្មភាពជាក់លាក់និងកម្មវិធីលម្អិតដើម្បីអនុវត្តគោលនយោបាយ** | | | | | | | |
| | | | មាននៅតាមសកម្មភាពនៃយុទ្ធសាស្ត្រទី២-ទី៩ | ដូចក្នុងសកម្មភាពត្រូវគ្នាក្នុងយុទ្ធសាស្ត្រទី២-៩ | ដូចក្នុងសកម្មភាពត្រូវគ្នាក្នុងយុទ្ធសាស្ត្រទី២-៩ | នា.នីតិ និងនាយកដ្ឋានពាក់ព័ន្ធ (អនុក្រឹត៨៤ | $0 |
| **យុទ្ធសាស្ត្រទី២. ទាក់ទាញអ្នកមានសមត្ថភាពឱ្យប្រកបរបរខ្លាជីវៈជាគ្រូបង្រៀន** | | | | | | | |
| **យុទ្ធសាស្ត្ររងទី២.១លើកកម្ពស់ជីវភាពតម្លៃវិជ្ជាជីវៈសេចក្តីថ្លៃថ្នូរនិងការយកចិត្តទុកដាក់ពីសង្គម** | | | | | | | |
| 2.1.1 | បន្តបង្កើនលាភការអប់រំនិងផលប្រយោជន៍វិជ្ជាជីវៈគ្រូបង្រៀន | 2.1.1.1 | បន្តកែលម្អប្រព័ន្ធលាភការអប់រំ ប្រាក់ឧបត្ថម្ភផ្សេងៗ បៀវត្សនិងលក្ខខណ្ឌបម្រើការងាររបស់គ្រូបង្រៀនដោយអនុលោមតាមលទ្ធភាពម៉ាក្រូសេដ្ឋកិច្ច និងចំណូលនៃថវិកាជាតិ | -បានបញ្ជូនសំណើកែលម្អបៀវត្សនិងលាភការទៅគណៈរដ្ឋមន្ត្រី<br>-មានប្រព័ន្ធលាភការ ប្រាក់ឧបត្ថម្ភផ្សេងៗនិងបៀវត្សថ្មី | -ត្រីមាសទី២(Q2) ឆ្នាំ2015<br><br>-2015 Q3 | នា.បល នា.ផក នា.នីតិ នា.ហវ (អនុក្រឹត៨៤) | $2,653,009,000 |
| 2.1.2 | លើកកម្ពស់តម្លៃវិជ្ជាជីវៈគ្រូបង្រៀនដោយមានការចូលរួមពីគ្រប់មជ្ឈដ្ឋាន(រដ្ឋ វិស័យឯកជន សហគមន៍ ដៃគូជាដើម) | 2.1.2.1 | ផ្តល់រង្វាន់(ជាប្រាក់និងមិនមែនជាប្រាក់)ដល់គ្រូបង្រៀនក្នុងទិវាគ្រូបង្រៀនដែលត្រូវរៀបចំនៅតាមមូលដ្ឋានដើម្បីបង្ហាញពីតម្លៃវិជ្ជាជីវៈនិងការទទួលខុសត្រូវខ្ពស់របស់គ្រូបង្រៀន | -ភាគរយនៃគ្រឹះស្ថានសិក្សាដែលប្រារព្ធទិវាគ្រូបង្រៀន<br>-ចំនួនគ្រូបង្រៀនដែលទទួលរង្វាន់ | 2015 Q4: 10%<br>2017 Q4: 50%<br>2020 Q4: 100% | គណៈកម្មការទ្រទ្រង់សាលារៀន គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា | $54,000 |
| | | 2.1.2.2 | បង្កើតយន្តការតវ៉ានៅគ្រប់ឋានានុក្រមរដ្ឋបាលអប់រំៈថ្នាក់ជាតិ ថ្នាក់ខេត្ត-ក្រុង ថ្នាក់ស្រុក-ខណ្ឌ និងថ្នាក់គ្រឹះស្ថានសិក្សា | បង្កើតយន្តការតវ៉ានៅថ្នាក់ក្រោមជាតិ | -ខេត្ត-ក្រុង ស្រុក-ខណ្ឌ 2015 Q1<br>-គ្រឹះស្ថានសិក្សា2016 Q1 | នា.នីតិ មន្ទីរអយក ការិ.អយក សាលារៀន | $0 |
| | | 2.1.2.3 | ពង្រឹងតួនាទីរបស់នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការដើម្បីគាំទ្រដល់គ្រូបង្រៀន ជាពិសេសដើម្បីឆ្លើយតបរាល់កង្វល់និងសំណួរ/ការងឿងឆ្ងល់វិជ្ជាជីវៈគ្រូបង្រៀន | បង្កើតការិយាល័យគាំទ្រគ្រូបង្រៀននៅនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | 2015 Q3 | ការិយាល័យគាំទ្រគ្រូបង្រៀន (នា.បវ) | $210,000 |
| | | 2.1.2.4 | រៀបចំឋានៈក្នុងក្របខ័ណ្ឌគន្លងអាជីពគ្រូបង្រៀន(គ្រូថ្មី គ្រូពេញសិទ្ធិ គ្រូមានបទពិសោធន៍) និងពិចារណាផ្តល់ឯកសណ្ឋានសម្រាប់គ្រូបង្រៀន | -ឋានៈគ្រូបង្រៀនត្រូវបានរៀបចំតាមគន្លងអាជីពគ្រូបង្រៀន<br>-សំណើរៀបចំឯកសណ្ឋានសម្រាប់គ្រូបង្រៀន | រាល់ឆ្នាំ<br><br>2016 Q4 | នា.បល នា.នីតិ នា.ហវ | នឹងពិចារណាតាមក្រោយ |
| | | 2.1.2.5 | ពិចារណាក្នុងការរៀបចំប្រាក់បំណាច់សម្រាប់តាំងទីលំនៅដល់គ្រូបង្រៀនថ្មីនិងបន្តកែលម្អប្រាក់បំណាច់សម្រាប់តំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក | -សំណើប្រាក់សម្រាប់តាំងទីលំនៅដល់គ្រូបង្រៀន<br>-មានគោលការណ៍ផ្តល់ប្រាក់បំណាច់សម្រាប់គ្រូបង្រៀនបម្រើការងារនៅតំបនដាច់ស្រយាលនិងតំបន់ជួបការលំបាក<br>-ចំនួនគ្រូបង្រៀនថ្មីឬគ្រូបង្រៀនដែលពង្រាយទៅតំបន់ជួបការលំបាកនិង ដាច់ស្រយាល | 2016 Q4<br><br>2016 Q4<br><br>-រាល់ឆ្នាំ | នា.បល នា.នីតិ នា.ហវ ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ | $6,000,000 |

| កម្មវិធី/សកម្មភាពគោល | កិច្ចការ/សកម្មភាព | សូចនាករ | ពេលបញ្ចប់សកម្មភាព | អង្គភាពទទួលខុសត្រូវ | ថវិកា(USD) |
|---|---|---|---|---|---|
| | 2.1.2.6 លើកទឹកចិត្តឱ្យគ្រូបង្រៀនចូលរួមផ្តល់មតិយោបល់ក្នុងការរៀបចំនិងអនុវត្តគោលនយោបាយក្នុងវិស័យអប់រំដើម្បីលើកស្ទួយនិងកែលម្អស្ថានភាពសង្គមរបស់គ្រូបង្រៀន | -ចំនួនគ្រូបង្រៀនដែលបានផ្តល់ព័ត៌មានត្រឡប់ស្តីពីការអនុវត្តគោលនយោបាយក្នុងវិស័យអប់រំ | -រាល់ឆ្នាំ | អង្គភាពដែលពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | $0 |
| 2.1.3 លើកកម្ពស់ភាពមិនរើសអើងក្នុងការចូលបម្រើវិជ្ជាជីវៈគ្រូបង្រៀន | 2.1.3.1 ផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ នារី ជនជាតិ និងពិការ (កម្រិតស្រាល)និងរៀនពូកែ ដើម្បីទាក់ទាញឱ្យចាប់យក វិជ្ជាជីវៈគ្រូបង្រៀន។ផ្តល់អាហារូបករណ៍ដល់សិស្សពូកែនារី នៅសាលាមធ្យមសិក្សានិងដល់សិស្សពូកែជាបុរសនៅមត្តេយ្យសិក្សា | កម្មវិធីអាហារូបករណ៍ចាប់ផ្តើម<br>-តុល្យភាពយេនឌ័រ<br>-ចំនួនគរុសិស្ស/គរុនិស្សិត ដែលពិការ ជនជាតិ នារី បុរស ... | 2015 Q3 | នា.បវ នា.ហវ គ្រឹះ.ប.បគ្រូបង្រៀន មន្ទីរអយក | $10,225,200 |
| **យុទ្ធសាស្ត្ររងទី២.២លើកកម្ពស់ការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀន** | | | | | |
| 2.2.1 រៀបចំគន្លងអាជីពគ្រូបង្រៀន | 2.2.1.1 បង្កើតគន្លងអាជីពគ្រូបង្រៀនតាមឧបនិស្ស័យ (បច្ចេកទេស គ្រប់គ្រង បង្រៀន)ដោយផ្អែកលើអតីតភាពនិងបទពិសោធន៍ការងារ | បញ្ចប់ការកសាងគន្លងអាជីពគ្រូបង្រៀន | 2016 Q1 | នា.បល នា.បវ (អនុក្រឹត៨៤) | $15,000 |
| | 2.2.1.2 អនុវត្តគន្លងអាជីពគ្រូបង្រៀន | ភាគរយនៃគ្រូបង្រៀនដែលបានទទួលគន្លងអាជីពគ្រូបង្រៀន | 2016 Q4: 100% | នា.បល នា.បវ (អនុក្រឹត៨៤) | $240,000 |
| 2.2.2 ផ្តល់ឱកាសឱ្យដល់គ្រូបង្រៀនស្មើៗគ្នាសម្រាប់អភិវឌ្ឍអាជីព | 2.2.2.1 សូមមើលយុទ្ធសាស្ត្រទី៦ | | | | |
| **យុទ្ធសាស្ត្ររងទី២.៣កំណត់លក្ខណវិនិច្ឆ័យនិងលក្ខខណ្ឌតម្រូវខាងវិជ្ជាជីវៈសម្រាប់ការជ្រើសរើស** | | | | | |
| 2.3.1 បង្កើតច្រកចូលច្រើនសម្រាប់វិជ្ជាជីវៈគ្រូបង្រៀន | 2.3.1.1 បង្កើតច្រកចូលច្រើនដើម្បីធ្វើជាគ្រូបង្រៀនដោយបើកទូលាយការបណ្តុះបណ្តាលបេក្ខជនបរិញ្ញាបត្រនៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈនិងគ្រឹះស្ថានឧត្តមសិក្សាឯកជនឱ្យទទួលបានអាជ្ញាបណ្ណគ្រូបង្រៀន | -ចំនួនអ្នកមានសញ្ញាបត្របរិញ្ញា បត្រទទួលបានអាជ្ញាបណ្ណគ្រូបង្រៀន | 2017 Q3 | នា.នីតិ នា.បវ គ្រឹះស្ថានប.បគ្រូបង្រៀន គ្រឹះស្ថានឧត្តមសិក្សា(អនុក្រឹត៨៤) | $0 |
| | 2.3.1.2 រៀបចំវគ្គបណ្តុះបណ្តាលសម្រាប់គ្រូ១២+២ឱ្យទទួលបានសញ្ញាបត្របរិញ្ញាបត្រដោយសហការជាមួយគ្រឹះស្ថានឧត្តមសិក្សា | ចំនួនគ្រូ១២+២ ដែលបានទទួលសញ្ញាបត្របរិញ្ញាបត្រ | 2015 Q3 | នា.បវ គ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានប.ប.គ្រូបង្រៀន | $3.150.000 |
| | 2.3.1.3 បើកច្រកឱ្យអ្នកដែលមានបរិញ្ញាបត្រឱ្យចូលបណ្តុះបណ្តាលក្លាយជាគ្រូកម្រិតមូលដ្ឋានតាមរយៈវគ្គបណ្តុះបណ្តាលគរុកោសល្យរយៈពេលខ្លីនៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន | -ដំណើរការវគ្គបណ្តុះបណ្តាល<br>-ចំនួនគរុនិស្សិត/គរុនិស្សិត<br>-ចំនួនគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន | -ផ្តើម៖2015 Q3<br>-រាល់ឆ្នាំមានគរុសិស្ស/គរុនិស្សិតដែលមានBAចំនួន 20%ចូលរៀនវគ្គបណ្តុះបណ្តាល<br>បញ្ចប់៖ 2020 | នា.នីតិ នា.បវ គ្រឹះស្ថាន ប.បគ្រូបង្រៀន(អនុក្រឹត៨៤) | សិក្សា៖ $6,000<br>អនុវត្ត $1,500,000 |

| កម្មវិធី/សកម្មភាពគោល | | កិច្ចការ/សកម្មភាព | | សូចនាករ | ពេលបញ្ចប់សកម្មភាព | អង្គភាពទទួលខុសត្រូវ | ថវិកា(USD) |
|---|---|---|---|---|---|---|---|
| 2.3.2 | សម្រិតសម្រាំងការប្រឡងចូលគ្រឹះស្ថាន បណ្តុះបណ្តាលគ្រូបង្រៀន | 2.3.2.1 | រឹតបន្តឹងការប្រឡងចូលគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន និងធ្វើចំណាត់ថ្នាក់ជាលក្ខណៈប្រកួតប្រជែងទូទាំងប្រទេសតាមចំនួនក្របខ័ណ្ឌដែលបានកំណត់។ លុបបំបាត់ចំណាត់ថ្នាក់តាមតំបន់។ | -លទ្ធផលការប្រឡងចូលគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន<br>-ធ្វើចំណាត់ថ្នាក់ជាលក្ខណៈប្រកួតប្រជែងទូទាំងប្រទេស | 2015 Q4: | នា.នីតិ នា.បវ គ្រឹះស្ថាន ប.ប គ្រូបង្រៀន(អនុក្រឹត៨៤) | ប្រើថវិកាកម្មវិធី |
| | | 2.3.2.2 | បេក្ខជនដែលមាននិទ្ទេស A, B និងCក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ចាប់ពីឆ្នាំសិក្សា២០១៣-១៤ តទៅនឹងជាប់ជាស្វ័យប្រវត្តិសម្រាប់ចូលសិក្សានៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន។ ក្នុងករណីចំនួនលើសពីការកំណត់ត្រូវមានការជ្រើសរើសសម្រាំងតាមលំដាប់ពិន្ទុឬតាមអាទិភាព | ចំនួនគ្រឹះស្ថានបណ្តុះបណ្តាលដែលទទួល សិស្សមាននិទ្ទេសA,B,C | 2015 Q3 | នា.នីតិ នា.បវ គ្រឹះស្ថាន ប.ប គ្រូបង្រៀន(អនុក្រឹត៨៤) | $0 |
| | | 2.3.2.3 | កែលម្អយន្តការប្រឡងចូលគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ១)ធានាគោលការណ៍ច្បាប់ យុត្តិធម៌ តម្លាភាព លទ្ធផលអាចទទួលយកបាន២)សំណេរ ៣)សម្ភាសផ្ទាល់ជាមួយបេក្ខជនដែលជាប់ក្នុងបញ្ជីបម្រុង៤)កែប្រែគោលការណ៍កំណត់អាយុ ៥)តាមដានពេលបណ្តុះបណ្តាល | -កែលម្អការប្រឡង<br>-សាកល្បងអនុវត្តការសម្ភាសនៅវិទ្យាស្ថានជាតិអប់រំ<br>-អនុវត្តការសម្ភាសនៅមជ្ឈ.ភូមិភាគ<br>-អនុវត្តការសម្ភាសនៅគ្រប់គ្រឹះបណ្តុះបណ្តាលគ្រូបង្រៀន | 2015 Q2<br>2015 Q4<br>2016 Q4<br>2017 Q4 | នា.នីតិ នា.បវ គ្រឹះស្ថាន ប.ប គ្រូបង្រៀន(អនុក្រឹត៨៤) | $15,000 |
| **យុទ្ធសាស្ត្រងទី២.៤ធ្វើទំនើបកម្មស្តង់ដារកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនឱ្យឆ្លើយតបនឹងតម្រូវការរបស់ជាតិនិងការប្រកួតប្រជែងក្នុងតំបន់និងសកលលោក** | | | | | | | |
| 2.4.1 | កសាងឯកសារបំពេញបន្ថែមលើស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន | 2.4.1.1 | ពិនិត្យឡើងវិញលើឯកសារ ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន | បញ្ចប់ការពិនិត្យ | 2015 Q4 | គ្រប់នាយកដ្ឋានពាក់ព័ន្ធ (អនុក្រឹត៨៤) | $2,000 |
| | | 2.4.1.2 | ចែកផ្សាយនិងបំប៉នគ្រូបង្រៀនទាំងអស់អំពីស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនដែលបានកែលម្អ (ដោយបញ្ជ្រាបក្នុងកម្មវិធីបណ្តុះ បណ្តាល វិក្រឹតការនិងការតម្រង់ទិសគ្រូបង្រៀនថ្មី) | -ភាគរយគ្រូបង្រៀនដែលទទួលបានឯកសារស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនដែលបានកែលម្អ<br>-ភាគរយគ្រូបង្រៀនដែលទទួលការបំប៉នលើឯកសារស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនដែលបានកែលម្អ | 2016 Q4: 100%<br>2016 Q4: 10%<br>2018 Q3: 50%<br>2020 Q3: 100% | នា.បវ ៉ការិយាល័យគាំទ្រគ្រូបង្រៀន៉ | $2,740,000 |
| 2.4.2 | កសាងឯកសារបំពេញបន្ថែមលើស្តង់ដារគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន | 2.4.2.1 | កសាងឯកសារបំពេញបន្ថែមលើស្តង់ដារគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន | បានរៀបចំស្តង់ដារគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន | 2015 Q1 | នា.ឧស គ្រឹះស្ថានឧត្តមសិក្សា នា.បវ នា.នីតិ (អនុក្រឹត៨៤) | $9,000 |
| | | 2.4.2.2 | តាមដានការអនុវត្តស្តង់ដារគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន និងប្រព័ន្ធធានាគុណភាពការងារបណ្តុះបណ្តាលគ្រូបង្រៀន | របាយការណ៍ពិនិត្យតាមដាន | 2016 Q1 | នា.ឧស ស្តង់ដារគ្រឹះស្ថានប.ប គ្រូបង្រៀន នា.បវ នា.នីតិ នា.ផក(អនុក្រឹត៨៤) | $1,130,000 |
| 2.4.3 | បង្កើតច្រកចូលច្រើនសម្រាប់ការបណ្តុះ | 2.4.3.1 | អនុវត្តការបណ្តុះបណ្តាលគ្រូបង្រៀនសាធារណៈតាមរូបមន្ត | -កសាងផែនការសម្រាប់សាកល្បង | 2016Q4 | នា.ឧស ស្តង់ដារគ្រឹះស្ថានប.ប | $400,000 |

| កម្មវិធី/សកម្មភាពគោល | កិច្ចការ/សកម្មភាព | សូចនាករ | ពេលបញ្ចប់សកម្មភាព | អង្គភាពទទួលខុសត្រូវ | ថវិកា(USD) |
|---|---|---|---|---|---|
| បណ្តាលគ្រូបង្រៀនដោយបញ្ចូល គ្រឹះស្ថានឧត្តមសិក្សាឱ្យ(សាកល្បង)ជួយ បណ្តុះបណ្តាល | បរិញ្ញាបត្របូក១នៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន (មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ)ដោយមានជំនួយ បច្ចេកទេសពីគ្រឹះស្ថានឧត្តមសិក្សា ដែលបានបំពេញលក្ខខណ្ឌ ស្តង់ដារគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនតាមគោលការណ៍ កំណត់របស់រាជរដ្ឋាភិបាល | បណ្តុះបណ្តាល តាមរូបមន្ត បរិញ្ញាបត្របូក១<br>-ចំនួនគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ដែលបណ្តុះបណ្តាលគ្រូតាមរូបមន្ត បរិញ្ញាបត្របូក១ (នៅភ្នំពេញនិង ខេត្តបាត់ដំបង) | ផ្តើម៖ 2018Q3<br>គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ចំនួន២ | គ្រូបង្រៀន នា.បវ នា.នីតិ នា. ផក (អនុក្រឹត៨៤) | |
| | 2.4.3.2 អនុវត្តការបណ្តុះបណ្តាលគ្រូបង្រៀនសម្រាប់គ្រឹះស្ថានឯកជន តាមរូបមន្តបរិញ្ញាបត្របូក១នៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ បង្រៀនដោយមានជំនួយបច្ចេកទេសពីគ្រឹះស្ថានឧត្តមសិក្សា ដែលទទួលស្គាល់ដោយស្តង់ដារគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ បង្រៀនដោយផ្តល់សញ្ញាបត្រ តែមិនធានាផ្តល់ការងារក្នុង ក្របខ័ណ្ឌរដ្ឋទេ | -ចំនួនគ្រឹះស្ថានឧត្តមសិក្សា(ទទួល ស្គាល់ដោយស្តង់ដារគ្រឹះស្ថានប ណ្តុះបណ្តាលគ្រូបង្រៀន)ធ្វើការប ណ្តុះបណ្តាលគ្រូបង្រៀនតាមរូបមន្ត បរិញ្ញាបត្របូក១ | 2020Q4:មានចំនួន៥ | នា.ឧស ស្តង់ដារគ្រឹះស្ថានប.ប គ្រូបង្រៀននា.បវ នា.នីតិ នា. ផក(អនុក្រឹត៨៤) | $80,000 |
| **យុទ្ធសាស្ត្រទី៣ កំណត់ស្តង់ដារប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន** | | | | | |
| យុទ្ធសាស្ត្ររងទី៣.១ធ្វើបច្ចុប្បន្នភាពប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន | | | | | |
| 3.1.1 រៀបចំការសិក្សាស្រាវជ្រាវលម្អិតអំពីប្រព័ន្ធ បណ្តុះបណ្តាលគ្រូបង្រៀនបច្ចុប្បន្ន | 3.1.1.1 សិក្សានិងវិភាគធនធាន និងរចនាសម្ព័ន្ធគ្រឹះស្ថានបណ្តុះ បណ្តាល គ្រូបង្រៀនដែលមានស្រាប់ | ការសិក្សាបានបញ្ចប់ | 2015 Q4 | អ្នកសិក្សាវាយតម្លៃឯករាជ្យ នា .បវ នា.ផក នា.អកស | $430,000 |
| | 3.1.1.2 កែសម្រួលរចនាសម្ព័ន្ធគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនឱ្យ ធានាបានតាមលក្ខខណ្ឌនៃការបំពេញភារកិច្ចរបស់ខ្លួន | បង្កើតការិ.ផែនការ ស្រាវជ្រាវក្នុង គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន | 2015 Q4 | នា.បវ នា.បលគ្រឹះស្ថានប.ប គ្រូបង្រៀន | $0 |
| | 3.1.1.3 គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀននីមួយៗធ្វើការសិក្សាវាយ តម្លៃអង្គភាពរបស់ខ្លួនធៀបនឹងស្តង់ដារគ្រឹះស្ថានបណ្តុះ បណ្តាលគ្រូបង្រៀន | ការសិក្សាបានបញ្ចប់ | 2016 Q3 | នា.បវ នា.ផក នា.ធគអ គ្រឹះស្ថានប,បគ្រូបង្រៀន | $24,000 |
| 3.1.2 កែទម្រង់កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន គ្រប់កម្រិត | 3.1.2.1 រៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានតាមរូប មន្ត12+4 (បរិញ្ញាបត្រអប់រំ) សម្រាប់សិស្សថ្នាក់ទី១២ ដែលជាប់ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នៅមជ្ឈមណ្ឌលគរុកោសល្យ ភូមិភាគដោយផ្តោតលើចិត្តគរុកោសល្យ ICTវិធីសាស្ត្របង្រៀន ភាសាបរទេស គណិតវិទ្យា និងវិទ្យាសាស្ត្រ | ការកសាងកម្មវិធីបណ្តុះបណ្តាល បានបញ្ចប់ | 2017 Q3 | នា.បវ ស្តង់ដារគ្រឹះស្ថានប.ប គ្រូបង្រៀន | $327,400 |
| | 3.1.2.2 រៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានតាមរូប មន្តបរិញ្ញាបត្របូក១ សម្រាប់អ្នកមានបរិញ្ញាបត្រនៅមជ្ឈ មណ្ឌលគរុកោសល្យភូមិភាគដោយផ្តោតលើចិត្តគរុកោសល្យ | ការកសាងកម្មវិធីបណ្តុះបណ្តាល បានបញ្ចប់ | 2017 Q3 | នា.បវ ស្តង់ដារគ្រឹះស្ថាន ប.ប គ្រូបង្រៀន | |

| កម្មវិធី/សកម្មភាពគោល | កិច្ចការ/សកម្មភាព | សូចនាករ | ពេលបញ្ចប់សកម្មភាព | អង្គភាពទទួលខុសត្រូវ | ថវិកា(USD) |
|---|---|---|---|---|---|
| | ICTវិធីសាស្រ្តបង្រៀន ភាសាបរទេស គណិតវិទ្យា និងវិទ្យាសាស្រ្ត | | | | |
| | 3.1.2.3 រៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម(បង្រៀននៅវិទ្យាល័យ)តាមរូបមន្តបរិញ្ញាបត្រជាន់ខ្ពស់បូក១សម្រាប់អ្នកមានបរិញ្ញាបត្រជាន់ខ្ពស់ ដោយផ្តោតលើចិត្តគរុកោសល្យ ICTវិធីសាស្រ្តបង្រៀន ភាសាបរទេស គណិតវិទ្យា និងវិទ្យាសាស្រ្ត | ការកសាងកម្មវិធីបណ្តុះបណ្តាលបានបញ្ចប់ | 2019 Q4<br>អនុវត្ត: 2020 | នា.បវ ស្តង់ដារគ្រឹះស្ថាន ប.ប គ្រូបង្រៀនវជអ | |
| | 3.1.2.4 ពង្រឹងកម្មសិក្សាគរុកោសល្យ និងគាំទ្រសាលាអនុវត្ត | កែលម្អរយៈពេលនិងរៀបចំផែនការគាំទ្រការធ្វើកម្មសិក្សាគរុកោសល្យ | 2017 Q3 | នា.បវ ស្តង់ដារគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនសាលាអនុវត្ត | |
| | 3.1.2.5 បញ្ជ្រាបការអប់រំបញ្ចូលគ្នានិងយេនឌ័រក្នុងការកែលម្អកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន | បញ្ចប់ការកែលម្អកម្មវិធីបណ្តុះបណ្តាលណ្តាល | 2017 Q3 | នា.បវ នា.អកស ស្តង់ដារគ្រឹះស្ថាន ប.ប គ្រូបង្រៀន (អនុក្រឹត៨៤) គណៈកម្មការជាតិអប់រំ សម្រាប់ទាំងអស់គ្នា | |
| 3.1.3 អនុវត្តការបណ្តុះបណ្តាលគ្រូបង្រៀនតាមស្តង់ដារគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន | 3.1.3.1 សាកល្បងអនុវត្តការបណ្តុះបណ្តាលគ្រូបង្រៀនតាមរូបមន្ត12+4 បរិញ្ញាបត្រអប់រំនៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនមជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួនពីរដោយប្រើជំនួយបច្ចេកទេសពីគ្រឹះស្ថានឧត្តមសិក្សា | -រៀបចំផែនការសាកល្បង<br>-ការសាកល្បងចាប់ផ្តើមនៅភ្នំពេញនិងបាត់ដំបង | 2017 Q3<br>2018 Q3 | នា.បវ គ្រឹះស្ថានឧត្តមសិក្សា គ្រឹះប.បគ្រូបង្រៀន- ភ្នំពេញនិងបាត់ដំបង | $800,000 |
| | 3.1.3.2 សាកល្បងអនុវត្តការបណ្តុះបណ្តាលគ្រូបង្រៀនតាមរូបមន្តបរិញ្ញាបត្របូក១នៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនចំនួនពីរ(មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ) ដោយប្រើជំនួយបច្ចេកទេសពីគ្រឹះស្ថានឧត្តមសិក្សា | -រៀបចំផែនការសាកល្បង<br>-ការសាកល្បងចាប់ផ្តើមនៅភ្នំពេញនិងបាត់ដំបង | 2017 Q3<br>2018 Q3 | នា.បវ គ្រឹះស្ថានឧត្តមសិក្សា គ្រឹះប.បគ្រូបង្រៀន-ភ្នំពេញនិងបាត់ដំបង | មើល 2.4.3.1 |
| | 3.1.3.3 អនុវត្តការបណ្តុះបណ្តាលគ្រូបង្រៀនតាមរូបមន្តបរិញ្ញាបត្រជាន់ខ្ពស់បូក១ នៅវិទ្យាស្ថានជាតិអប់រំ | -រៀបចំផែនការ<br>-អនុវត្ត | 2019 Q3<br>2020 Q3 | វជអ | ប្រើថវិកាកម្មវិធី |
| **យុទ្ធសាស្ត្ររងទី៣.២បង្កើនប្រសិទ្ធភាពកម្មសិក្សាមុនពេលតាំងស៊ប់ក្នុងក្របខ័ណ្ឌ** | | | | | |
| 3.2.1 លើកកម្ពស់កម្មសិក្សានៅតាមសាលារៀន | 3.2.1.1 រៀបចំឯកសារជំនួយសម្រាប់កម្មសិក្សាការី/កម្មសិក្សាការិនីៈស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន ការណែនាំអំពីស្វ័យភាពគ្រូបង្រៀន គន្លងអាជីពគ្រូបង្រៀនព្រឹត្តិបត្រវាយតម្លៃការបណ្តុះបណ្តាលគ្រូបង្រៀននិងឯកសារនានាដែលទាក់ទងនឹងគ្រូបង្រៀន | ផ្តល់ឯកសារជំនួយសម្រាប់បណ្តុះបណ្តាល គរុសិស្ស/គរុនិស្សិតរៀងរាល់ឆ្នាំ | ផ្តើម៖2016Q3 | នា.បវ. គ្រឹះស្ថានប.ប គ្រូបង្រៀន គ្រប់នាយកដ្ឋាន (អនុក្រឹត៨៤) | $120,000 |
| | 3.2.1.2 បង្កើតប្រព័ន្ធទំនុកបម្រុងគាំទ្រគ្រូបង្រៀននៅនឹងសាលារៀន | បង្កើតក្រុមពិនិត្យតាមដាននៅថ្នាក់គ្រឹះស្ថានសិក្សា | ផ្តើម៖2017 Q3 | នា.នីតិ មន្ទីរអយក ការិ.អយក (អនុក្រឹត៨៤) | $240,000 |

| កម្មវិធី/សកម្មភាពគោល | កិច្ចការ/សកម្មភាព | សូចនាករ | ពេលបញ្ចប់សកម្មភាព | អង្គភាពទទួលខុសត្រូវ | ថវិកា(USD) |
|---|---|---|---|---|---|
| | | | | | |
| | 3.2.1.3 បន្ថយម៉ោងបង្រៀនរបស់គ្រូដែលមានបទពិសោធន៍ខ្ពស់ដើម្បីឱ្យពួកគាត់មានពេលវេលាច្រើនក្នុងការផ្តល់សេវាជួយដល់សកម្មភាពកម្មសិក្សា និងការណែនាំផ្ទាល់(សូមមើលនិយាមប្រើប្រាស់បុគ្គលិកអប់រំ និងគន្លងអាជីពគ្រូបង្រៀន) | ចំនួនគ្រូបង្រៀនដែលមានបទពិសោធន៍បានជួយនិងណែនាំគ្រូបង្រៀនថ្មីក្នុងសាលារៀន | ផ្តើម៖2017Q1 | នា.បល នា.បវ គ្រឹះស្ថានសិក្សា | $0 |
| **យុទ្ធសាស្ត្ររងទី៣.៣.កំណត់កម្រិតស្វ័យភាពរបស់គ្រូបង្រៀន** | | | | | |
| 3.3.1 ជំរុញការអនុវត្តស្វ័យភាពរបស់គ្រូបង្រៀនពិសេសនៅថ្នាក់គ្រឹះស្ថានសិក្សា | 3.3.1.1 អភិវឌ្ឍឯកសារការណែនាំអំពីស្វ័យភាពរបស់គ្រូបង្រៀន | កសាងឯកសារណែនាំស្វ័យភាពរបស់គ្រូបង្រៀន | 2016Q1 | នា.បល នា.បវ គ្រប់នាយកដ្ឋាន (អនុក្រឹត៨៤) | $9,000 |
| | 3.3.1.2 ចែកផ្សាយឯកសារការណែនាំអំពីស្វ័យភាពរបស់គ្រូបង្រៀន | គ្រូបង្រៀនទាំងអស់ទទួលបានឯកសារណែនាំស្វ័យភាពរបស់គ្រូបង្រៀន | 2016Q4 | នា.បល មន្ទីរអយក ការិ. អយក សាលារៀន | $240,000 |
| | 3.3.1.3 ធានាថាគ្រូបង្រៀនមានសិទ្ធិក្នុងការជ្រើសរើសសម្ភារៈវិធីសាស្ត្រសម្រាប់បង្រៀននិងរបៀបវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស | អនុវត្តការណែនាំស្វ័យសិក្សា | 2016Q4 | អធិការដ្ឋាន នា.ធគអ មន្ទីរអយក ការិ.អយក | $0 |
| **យុទ្ធសាស្ត្រទី៤ អភិវឌ្ឍគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន** | | | | | |
| **យុទ្ធសាស្ត្ររងទី៤.១អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន** | | | | | |
| 4.1.1 បំពាក់សម្ភាររូបវន្តដល់គ្រប់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនទាំងអស់ឱ្យស្របតាមស្តង់ដារគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន | 4.1.1.1 (ផ្អែកតាមលទ្ធផលសិក្សានៅ 3.1.1. និងស្តង់ដារស្តង់ដារគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន)កែលម្អហេដ្ឋារចនាសម្ព័ន្ធរបស់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន រួមទាំងការផ្តល់សម្ភារឧបទេស(រៀននិងបង្រៀន) បរិក្ខារឧបករណ៍ICTបន្ទប់ពិសោធន៍ បង្គន់អនាម័យ អន្តេវាសិកដ្ឋាន ។ល។ | -បំពាក់សម្ភាររូបវន្តដល់គ្រឹះស្ថាន បណ្តុះបណ្តាលគ្រូបង្រៀននៅភ្នំពេញនិងបាត់ដំបងដែលត្រូវអនុវត្តការសាកល្បង | ផ្តើម៖ 2016Q2<br>បញ្ចប់៖ 2018Q4 | នា.បវ គ្រឹះស្ថានប.ប.គ្រូ នា.ហរ នា.ផក នា.ទសរ | $8,514,300 |
| | 4.1.1.2 សង់បន្ទប់ពិសោធន៍វិទ្យាសាស្ត្របន្ថែមនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនចំនួន១៤ | បានសង់បន្ទប់ពិសោធន៍ វិទ្យាសាស្ត្រ | 2019Q4 | នា.បវ គ្រឹះស្ថានប.ប.គ្រូ នា.សំណង់ | $850,000 |
| **យុទ្ធសាស្ត្ររងទី៤.២ប្រែក្លាយសាលាគរុកោសល្យឱ្យទៅជាមជ្ឈមណ្ឌលអភិវឌ្ឍគ្រូបង្រៀន** | | | | | |
| 4.2.1 ប្រែក្លាយគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនទៅជាវិទ្យាស្ថានបណ្តុះបណ្តាលគ្រូបង្រៀន | 4.2.1.1 ក្រោយពីបានបំពេញតាមលក្ខខណ្ឌស្តង់ដារគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនដាក់ពាក្យសុំទទួលស្គាល់ជាផ្លូវការជាវិទ្យាស្ថានបណ្តុះបណ្តាលគ្រូបង្រៀន | ប្រែក្លាយមជ្ឈមណ្ឌលភូមិភាគចំនួនពីរទៅជាវិទ្យាស្ថានបណ្តុះបណ្តាលគ្រូបង្រៀន(ភ្នំពេញនិងបាត់ដំបង) | 2018 Q2 | នា.នីតិ នា.បវ នា.បល នា.ផក គ្រឹះស្ថានប.បគ្រូបង្រៀន | $8,514,300 |
| **យុទ្ធសាស្ត្ររងទី៤.៣បង្កើនគុណវុឌ្ឍិនិងបទពិសោធន៍បុគ្គលិកអប់រំនៅមជ្ឈមណ្ឌលអភិវឌ្ឍគ្រូបង្រៀន** | | | | | |

| កម្មវិធី/សកម្មភាពគោល | កិច្ចការ/សកម្មភាព | សូចនាករ | ពេលបញ្ចប់សកម្មភាព | អង្គភាពទទួលខុសត្រូវ | ថវិកា(USD) |
|---|---|---|---|---|---|
| 4.3.1 បង្កើនសមត្ថភាពបុគ្គលិកបង្រៀនទាំងអស់នៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនឱ្យស្របតាមស្តង់ដារគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន | 4.3.1.1 រៀបចំកម្មវិធីបង្កើនសមត្ថភាពគ្រូឧទ្ទេសនៅតាមគ្រឹះស្ថាន ឧត្តមសិក្សាឬគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនដទៃទៀត ដែលទទួលស្គាល់ដោយស្តង់ដារគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន | ចំនួនអ្នកមានបរិញ្ញាបត្រដែលបានធ្វើវិក្រឹតការឱ្យទទួលបានសញ្ញាបត្រជាន់ខ្ពស់ | 2015 -2020 គ្រូឧទ្ទេសចំនួន៥០នាក់ ធ្វើវិក្រឹតការរៀងរាល់ឆ្នាំ | គ្រឹះ.ឧត្តមសិក្សា នា.បវ ស្តង់ដារគ្រឹះស្ថានប.បគ្រូបង្រៀន | $1,552,000 |
| | 4.3.1.2 ជ្រើសរើសគ្រូឧទ្ទេសថ្មីពេញម៉ោងចេញពីចំណោមអ្នកដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ឬបណ្ឌិតឬអ្នកដែលមានបទពិសោធន៍បង្រៀនខ្ពស់ ទាំងចំណេះដឹងមុខវិជ្ជា បទពិសោធន៍ ភាសាបរទេស ITនិងសីលធម៌វិជ្ជាជីវៈ) | គ្រូឧទ្ទេសរើសថ្មីដែលមានគុណវុឌ្ឍិបរិញ្ញាបត្រជាន់ខ្ពស់ចំនួន១០០០ នាក់ និងបណ្ឌិតចំនួន ៣០នាក់ | 2015 -2020 | នា.បល នា.ផក នា.បវ | $7,421,000 |
| | 4.3.1.3 អភិវឌ្ឍសមត្ថភាពគ្រូឧទ្ទេសដែលមានស្រាប់នៅគ្រឹះស្ថានបណ្តុះបណ្តាល គ្រូបង្រៀនឱ្យមានសមត្ថភាពយ៉ាងទាបបរិញ្ញាបត្រជាន់ខ្ពស់ | ចំនួនគ្រូឧទ្ទេសនៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនដែលមានគុណវុឌ្ឍិយ៉ាងទាបបរិញ្ញាបត្រជាន់ខ្ពស់ | 2015 -2020 | នា.បល នា.ផក នា.បវ គ្រឹះស្ថានប.បគ្រូបង្រៀន | មើល 6.1.2.4 ប្រើថវិកាដំណើរការសាលារៀន |
| យុទ្ធសាស្ត្ររងទី៤.៤ពង្រឹងមុខងាររបស់មជ្ឈមណ្ឌលអភិវឌ្ឍគ្រូបង្រៀនដើម្បីបន្តអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន | | | | | |
| 4.4.1 ពង្រីកតួនាទីបណ្តុះបណ្តាលនិងវិក្រិតការរបស់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន | 4.4.1.1 បណ្តុះបណ្តាលអធិការ | ចំនួនអធិការដែលបានបណ្តុះ បណ្តាល | 2015អធិការចំនួន៥០នាក់ 2018 | វជអ នា.បវ នា.បល នា.ផក | $33,509,484 |
| | 4.4.1.2 ពង្រឹងសមត្ថភាពមជ្ឈមណ្ឌលគរុកោសល្យភូមិភាគមួយចំនួនសម្រាប់បណ្តុះបណ្តាលនាយកគ្រឹះស្ថានសិក្សា | -ចំនួនមជ្ឈមណ្ឌលគរុកោសល្យភូមិភាគដែលបានជ្រើសរើស<br>-ចំនួននាយកគ្រឹះស្ថានសិក្សាដែលបានបណ្តុះបណ្តាល | 2017<br>ផ្តើម៖2015 | វជអ នា.ផក នា.បល នា.បវ មជ្ឈមណ្ឌលគរុ.ភូមិភាគ | $72,000 |
| | 4.4.1.3 បណ្តុះបណ្តាល/វិក្រឹតការអ្នកគ្រប់គ្រងអប់រំ (ថ្នាក់ក្រសួង មន្ទីរ អយក ការិ.អយក) | ចំនួនអ្នកគ្រប់គ្រងអប់រំដែលបាន បណ្តុះបណ្តាល | ផ្តើម៖2015 | វជអ មជ្ឈមណ្ឌលគរុ.ភូមិភាគ នា.បវនា.បល នា.ផក | $416,000 |
| **យុទ្ធសាស្ត្រទី៥ ធ្វើសនិទានកម្មគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់គ្រឹះស្ថានសិក្សា** | | | | | |
| យុទ្ធសាស្ត្ររងទី៥.១ធ្វើទំនើបកម្មផែនការតម្រូវការនិងផ្គត់ផ្គង់គ្រូបង្រៀនសម្រាប់ការបណ្តុះបណ្តាលមុនពេលបម្រើការងារ | | | | | |
| 5.1.1 ធ្វើសុខដុមនីយកម្មទិន្នន័យដើម្បីបង្កើនប្រសិទ្ធភាពការធ្វើផែនការគ្រូបង្រៀន | 5.1.1.1 ធ្វើសមាហរណកម្មទិន្នន័យពីគ្រប់ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ (EMIS, HRMIS, HEMIS, NFEMIS, FMIS) | មានសូចនាករទិន្នន័យថ្មី | 2015 Q4 | នា.បវ នា.ផក នា.បល គ្រឹះស្ថានប.បគ្រូបង្រៀន | $36,400 |
